ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORT

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ការប្រមូលអាករបំភ្លឺសាធារណៈរបស់
# អគ្គនាយកដ្ឋានពន្ធដារ

PUBLIC LIGHT TAX COLLECTION AT
GENERAL DEPARTMENT OF TAXATION

ជំនាញ៖ សវនកម្ម

រៀបរៀងដោយ៖ ហេ សុផាន់ណារ័ត្ន

អត្តលេខ៖ MA21/023

ឆ្នាំសិក្សា៖ ឆ្នាំ២០២៣-២០២៥

# ក្រសួងអប់រំ យុវជន និងកីឡា

**MINISTRY OF EDUCATION YOUTH AND SPORT**

# សាកលវិទ្យាល័យវ៉ាន់ដា

**VANDA UNIVERSITY**

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ការប្រមូលអាករបំភ្លឺសាធារណៈរបស់
# អគ្គនាយកដ្ឋានពន្ធដារ

PUBLIC LIGHT TAX COLLECTION AT
GENERAL DEPARTMENT OF TAXATION

**ជំនាញ៖ សវនកម្ម**

**សាស្ត្រាចារ្យណែនាំ៖ បណ្ឌិត កង ឌិម**

**លោកគ្រូណែនាំ៖ បេក្ខបណ្ឌិត យ៉ែម សុខហៀក**

**ឆ្នាំសិក្សា៖ ឆ្នាំ ២០២៣-២០២៥**

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី២១**

**ប្រធានបទៈ ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ**

| | |
|---|---|
| សាស្ត្រាចារ្យណែនាំ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត យ៉ែម សុខហៀក | បណ្ឌិត កង ឱម |
| សាកលវិទ្យាធិការរងអចិន្ត្រៃយ៍ | នាយកមជ្ឈមណ្ឌលស្រាវជ្រាវ |
| បណ្ឌិត ហ៊ូ គុជគន្ធលីនណា | បណ្ឌិត សេង សំអឿន |

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេខ វ៉ាន់ដា**

# ឧទ្ទិសស្នាដៃ

នាងខ្ញុំឈ្មោះ **ហេ សូផាន់ណារ័ត្ន** ជាបេក្ខជនបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញ **សវនកម្ម** ជំនាន់ទី២១ នៃ សាកលវិទ្យាល័យវ៉ាន់ដា

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធវីរព្រះមហាក្សត្រខ្មែរគ្រប់សម័យកាលដែលព្រះអង្គបានធ្វើព្រះរាជបូជនីយកិច្ចដើម្បីបុព្វហេតុជាតិនិងមាតុភូមិ។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះវិញ្ញាណក្ខន្ធមេដឹកនាំខ្មែរគ្រប់សម័យកាលដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ ប្រជាជន និងទឹកដី។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី កុលបុត្រ កុលធីតា និងជនរួមជាតិខ្មែរគ្រប់រូប ពុទ្ធបរិស័ទខ្មែរ និងជនស្នេហាជាតិទាំងអស់ ដែលបានធ្វើពលិកម្ម នៅគ្រប់សម័យកាលដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាពលរដ្ឋរបស់យើងទាំងអស់គ្នា។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះពុទ្ធបរិស័ទខ្មែរ និងជនស្នេហាជាតិទាំងអស់ដែលបានលះបង់ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិមាតុភូមិ។

សូមឱ្យមាតុភូមិកម្ពុជា ស្ថិតនៅគង់វង្ស មានភាពរុងរឿងសម្បូរសប្បាយ មានភាពថ្លៃថ្នូរ និងថ្កុំថ្កើងតរៀងទៅ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញសវនកម្មនៅសាកលវិទ្យាល័យវ៉ាន់ដាអស់រយៈពេលពីរឆ្នាំសិក្សារួចមកហើយ នាងខ្ញុំបានទទួលនូវចំណេះដឹងយ៉ាងច្រើនដែលពាក់ព័ន្ធនឹងមុខវិជ្ជា សវនកម្ម គណនេយ្យ ពន្ធដារជាពិសេសយល់ច្បាស់ថាជំនាញសវនកម្មគឺជាជំនាញមួយដ៏មានសារៈសំខាន់សម្រាប់តម្រូវការស្ថាប័នទាំងអស់មិនថាស្ថាប័នរដ្ឋ ឬស្ថាប័នឯកជន ឬក៏អង្គការក្រៅរដ្ឋាភិបាលឡើយ។ ក្នុងនោះផងដែរដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែស៊ីជម្រៅលើជំនាញរបស់ខ្លួន សាកលវិទ្យាល័យវ៉ាន់ដាក៏បានបញ្ចូលមុខវិជ្ជាជាច្រើនដែលពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សាទៅតាមកម្រិតពីឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទីពីរដែលត្រូវបញ្ចប់ការសិក្សា។

គ្រប់មុខវិជ្ជាទាំងអស់សុទ្ធតែជាយានសម្រាប់ឱ្យនិស្សិតយកទៅប្រើប្រាស់ នៅក្នុងវិស័យការងារបានជាពិសេសនោះគឺមុខវិជ្ជាពន្ធដារដែលស្ថាប័នត្រូវឱ្យបុគ្គលិកពាក់ព័ន្ធត្រូវមានចំណេះដឹងដើម្បីរៀបចំ និងកាន់កាប់បញ្ជី និង របាយការណ៍ឱ្យបានត្រឹមត្រូវ៩ស្របទៅតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីជៀសវាងនូវបញ្ហាផ្សេងៗដែលអាចកើតមានឡើង និងធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការអាជីវកម្មទៅថ្ងៃក្រោយ។

ដោយនាងខ្ញុំយល់ថា ចំណេះដឹងខាងពន្ធដារជាចំណេះដឹងបន្ថែមមួយទៀតដ៏មានសារៈសំខាន់សម្រាប់សវនករទាំងអស់ធ្វើការសិក្សាបន្ថែម និងស្របពេលដែលនាងខ្ញុំមានឱកាសបានសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផងនោះ ទើបនាងខ្ញុំបានសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **«ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយដ្ឋានពន្ធដារ»** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជារបាយការណ៍ក្នុងគោលបំណងឱ្យអ្នកអាន និងអ្នកស្រាវជ្រាវក្រោយៗទៀតឱ្យយល់កាន់តែច្បាស់ពីពន្ធ។

នាងខ្ញុំសង្ឃឹមថា ការរៀបចំរបាយការណ៍ស្រាវជ្រាវនេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗព្រមទាំងអ្នកដទៃទៀតដែលមានបំណងលើការសិក្សាពីជំនាញពន្ធដារ។

ជាទីបញ្ចប់ នាងខ្ញុំសូមមេត្តាខន្តីអភ័យទោសពីសំណាក់ សាស្រ្តាចារ្យ រាមច្បង និង មិត្តអ្នកអាននូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ហើយនាងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយៗទៀតមានភាពល្អប្រសើរ។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២១ ជំនាញសវនកម្មនៃសាកលវិទ្យាល័យវ៉ាន់ដា

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

លោកឪពុក និងអ្នកម្តាយទាំងពីរជាអ្នកមានគុណដែលបានផ្តល់កំណើត ហើយខិតខំប្រឹងប្រែងបីបាច់ថែរក្សាកូន ព្រមទាំងផ្គត់ផ្គង់ដល់កូនគ្រប់សព្វបែបយ៉ាងដើម្បីអោយកូនរៀនអោយបានខ្ពង់ខ្ពស់តាំងពីថ្នាក់បឋមរហូតមកដល់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បន្ថែមពីនេះទៅទៀតគាត់ខិតខំលើកទឹកចិត្តកូនក្នុងការសិក្សា និងបានបង្រៀនកូនឱ្យចេះស្នេហាជាតិមាតុភូមិកម្ពុជា។

អ្នកមានគុណបន្ទាប់ពីលោកឪពុក ម្តាយ គឺ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សាលារៀនដែលបានណែនាំបង្ហាត់បង្រៀន ផ្ទេរចំណេះវិជ្ជា ដូចនេះក្នុងនាមខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២១ ជំនាញសវនកម្មនៃសាកលវិទ្យាល័យវ៉ាន់ដា សូមគោរពអរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកនាយកគណៈគ្រប់គ្រងបុគ្គលិកសាស្ត្រាចារ្យនៃសាកលវិទ្យាល័យវ៉ាន់ដាដែលជានិច្ចកាលតែងតែផ្តល់ការលើកទឹកចិត្តអនុគ្រោះដល់នាងខ្ញុំរហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្ត្រាចារ្យ **បណ្ឌិត កង ឱម** និង **បេក្ខបណ្ឌិត យ៉ែម សុខហៀក** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃដើម្បីជួយណែនាំដល់ការសរសេររបាយការណ៍របស់នាងខ្ញុំឱ្យរឹតតែមានភាពល្អប្រសើរ។

ជាទីបញ្ចប់ នាងខ្ញុំសូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឱ្យជួបតែសេចក្តីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

**សូមអរគុណ**!

# អំណះអំណាង

នាងខ្ញុំសូមធានាអះអាង និងទទួលខុសត្រូវលើខ្លឹមសារដែលមាននៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ថារាល់របាយការណ៍ស្រាវជ្រាវទាំងអស់នេះ គឺពិតជាស្នាដៃដែលនាងខ្ញុំបានស្រាវជ្រាវផ្ទាល់ដៃរបស់នាងខ្ញុំពិតប្រាដកមែនដោយមានការណែនាំ និងសម្របសម្រួលពីសំណាក់ លោកបណ្ឌិត កង ឱម។

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២.......

**ហត្ថលេខា**

ថ្ងៃ..................ខែ................ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦.....

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២.......

**គ្រូណែនាំ**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

យោងតាមច្បាប់ពន្ធដារស្តីពីអាករបំភ្លឺសាធារណៈ (Public Lighting Tax) ពន្ធនេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ តាមមាត្រា២៣។ ប៉ុន្តែ មាត្រា២៣នេះត្រូវបានប្តូរទៅជាមាត្រា២៣ថ្មីដោយធ្វើវិសោធនកម្មលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០២ ចំពោះតម្លៃស្រា ស្រាបៀរ និងបារីដែលលក់នៅក្នុងដែនដីខេត្តក្រុង។ ដូចនេះមាត្រាទី២៣នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ត្រូវបានទុកនិរាករណ៍។ បន្ថែមពីនេះទៅទៀត ប្រកាសអន្តរក្រសួងលេខ១៧៥ សហវ. ពដ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០២២ ស្តីពីការគ្រប់គ្រងនិងការប្រមូលអាករបំភ្លឺសាធារណៈ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើនិយ័តកម្មលើការអនុវត្ត និងការប្រមូលអាករបំភ្លឺសាធារណៈ។ ជាពិសេសទៅទៀត យើងសង្កេតឃើញថានៅក្នុងឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានចេញប្រកាសថ្មីនិយ័តកម្មស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ ដែលមានចែងនៅក្នុងប្រកាសអន្តរក្រសួងលេខ១៩៨ សហវ.ប្រក.អពដ ចុះនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤។

បុគ្គលដែលធ្វើការផ្គត់ផ្គង់ស្រា ស្រាបៀរ និង បារី គឺជាបុគ្គលជាប់អាករបំភ្លឺសាធារណៈ និងទទួលខុសត្រូវចំពោះអាករនេះ។ បុគ្គលជាប់អាករត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់អាករសម្រាប់បំភ្លឺសាធារណៈដែលត្រូវបានអនុវត្តតែលើការផ្គត់ផ្គង់ដំបូងប៉ុណ្ណោះនៃផលិតផលដែលត្រូវបង់ពន្ធបន្ទាប់ពីផលិត ឬនាំចូលនៅកម្ពុជា។

# Research Summary

According to tax law provisions, the Public Lighting Tax (PLT) was originally established under the Law on Financial Management for the 1999 fiscal year, specifically under Article 23. However, this provision was later amended and replaced by a new Article 23 through a revision enacted under the Law on Financial Management for the 2002 fiscal year. The amendment specifically applied to the pricing of alcoholic beverages, beer, and tobacco products sold within provincial and municipal territories. Consequently, the original Article 23 of the 1999 law was rendered obsolete and no longer applicable.

The Public Lighting Tax (PLT) in Cambodia is an indirect tax levied on the supply of alcohol and tobacco products, serving as a fiscal instrument to generate government revenue while regulating the consumption of these goods. On 20 March 2024, the Ministry of Economy and Finance (MEF) issued Prakas No. 168, which revised the PLT rate from 3% to 5%, reflecting the government's policy shift towards increased taxation on excisable goods. The tax is calculated on the selling price, excluding Value Added Tax (VAT) and PLT, and is imposed only once at the point of initial supply. For imported goods, PLT is applied upon the first sale after importation, whereas for locally produced goods, the tax is imposed upon their first sale post-production. Notably, subsequent resellers are not subject to PLT, as the tax liability does not extend beyond the initial transaction. This policy framework ensures a single-stage taxation system, reducing tax cascading effects while maintaining regulatory oversight over the distribution of alcohol and tobacco products in Cambodia.

Furthermore, the Inter-Ministerial Prakas No. 175 MEF-GDT, dated January 22, 2022, was issued to regulate and oversee the implementation and collection of the Public Lighting Tax. This prakas played a significant role in establishing the regulatory framework governing the enforcement and administration of PLT in Cambodia.

In 2024, the Ministry of Economy and Finance (MEF) issued a new regulatory prakas concerning the Public Lighting Tax, officially documented under Inter-Ministerial Prakas No. 198 MEF-GDT, dated March 20, 2024. This prakas introduced further regulatory adjustments aimed at enhancing tax compliance and enforcement mechanisms for businesses subject to PLT.

Under this legal framework, entities engaged in the supply of alcoholic beverages, beer, and tobacco products are designated as PLT taxpayers and bear full legal responsibility for fulfilling their tax obligations. Taxpayers are required to submit tax declarations and remit PLT payments in accordance with the regulations. Notably, PLT is imposed only at the initial supply stage, meaning it applies to the first sale following either the production or importation of taxable products into Cambodia. Subsequent resales within the domestic market are not subject to additional PLT liability.

# មាតិកា

ទំព័រ

ឧទ្ទិសស្នាដៃ ........................................ i
អារម្ភកថា ........................................ ii
សេចក្តីថ្លែងអំណរគុណ ........................................ iii
អំណះអំណាង ........................................ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........................................ v
Research Summary ........................................ vi

**ជំពូកទី១: សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ១
១.៣ គោលបំណងនៃការស្រាវជ្រាវ ........................................ ២
១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៣

**ជំពូកទី២: រំលឹកទ្រឹស្តី**

២.១ លក្ខណៈទូទៅនៃការប្រមូលអាករបំភ្លឺសាធារណៈ ........................................ ៤
 ២.១.១ និយមន័យអាករបំភ្លឺសាធារណៈ ........................................ ៤
 ២.១.២ ប្រវត្តិអាករបំភ្លឺសាធារណៈ ........................................ ៥
 ២.១.៣ ទំនិញដែលជាប់អាករបំភ្លឺសាធារណៈ ........................................ ៥
២.២ ការកំណត់ពន្ធនៃអាករបំភ្លឺសាធារណៈ ........................................ ៧
 ២.២.១ និយមន័យពន្ធ ........................................ ៧
 ២.២.២ ប្រវត្តិពន្ធ ........................................ ៧
 ២.២.៣ ប្រភេទពន្ធ ........................................ ៨
 ២.២.៤ ច្បាប់នឹងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ ........................................ ៩
២.៣ ការប្រមូលអាករបំភ្លឺសាធារណៈ ........................................ ១២
 ២.៣.១ និយមន័យ ........................................ ១២
 ២.៣.២ ប្រវត្តិនៃអាករ ........................................ ១២
 ២.៣.៣ ការគណនាអាករសម្រាប់បំភ្លឺសាធារណៈ ........................................ ១៣

## ជំពូកទី៣: លទ្ធផលនៃការស្រាវជ្រាវ


៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ ........ ១៤

៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១៤

៣.១.២ ទស្សនវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១៥

៣.១.៣ បេសកកម្ម ........ ១៥

៣.១.៤ គុណតម្លៃរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១៥

៣.១.៥ និមិត្តសញ្ញានិងរចនាសម្ព័ន្ធរបស់អគ្គនាយដ្ឋានពន្ធដារ ........ ១៥

៣.២ ការកំណត់ពន្ធនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១៧

៣.២.១ ការបង្កើតអាករបំភ្លឺសាធារណៈ ........ ១៧

៣.២.២ បុគ្គលជាប់អាករ ........ ១៨

៣.២.៣ ទំនិញជាប់អាករ ........ ១៩

៣.៣ វិធីនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ២០

៣.៣.១ ការប្រមូលប្រាក់អាករ ........ ២០-២៣


## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ


៤.១ ការវិភាគលើចំណុចខ្លាំង ........ ២៤

៤.២ ការវិភាគលើចំណុចខ្សោយ ........ ២៤


## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍


៥.១ សេចក្តីសន្និដ្ឋាន ........ ២៥

៥.២ ការផ្តល់អនុសាសន៍ ........ ២៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសកំពុងអភិវឌ្ឍន៍ និង ធ្វើការប្រកួតប្រជែងក្នុងវិស័យសេដ្ឋកិច្ចដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សជាពិសេសនៅក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។ វិស័យទាំងអស់នេះគឺជាស្នូលក្នុងការជំរុញសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ក្នុងកាលៈទេសៈបច្ចុប្បន្ននេះផ្នែកសម្របសម្រួលពន្ធនឹងមានការកែលំអមុខងារនិងច្បាប់ដើម្បីលើកកម្ពស់ការវិនិយោគ ជាពិសេសពន្ធនិងប្រាក់ឈ្នួលដែលមានភាពងាយស្រួលសម្រាប់អ្នកវិនិយោគ។ ការគ្រប់គ្រងសេដ្ឋកិច្ច និងការកំណត់ពន្ធដែលប្រកបដោយភាពច្បាស់លាស់ជួយឱ្យកម្ពុជាជួយសម្រួលការអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ចនៅលើកម្រិតជាតិ និងអន្តរជាតិ។

គោលនយោបាយសារពើពន្ធ ជាគោលនយោបាយសំខាន់មួយដ៏សំខាន់ ដែលត្រូវបានគ្រប់គ្រងដោយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីតាមដានចំណូល និងចំណាយរបស់រាជរដ្ឋាភិបាលតាមរយៈការប្រមូលពន្ធពីប្រជាពលរដ្ឋ រូបវន្តបុគ្គល និង នីតិបុគ្គល ដែលមានសិទ្ធិជាប់ពន្ធ។ ពន្ធដែលត្រូវប្រមូលរួមមាន ដូចជា ពន្ធអាករបំភ្លឺសាធារណៈ ពន្ធលើអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ពន្ធប៉ាតង់ពន្ធប្រចាំឆ្នាំ ដូចជា ពន្ធប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធកាត់ទុក ពន្ធលើប្រាក់បៀវត្ស ពន្ធផ្សេងៗទៀត។

ការប្រមូលពន្ធដារ មានតួនាទីសំខាន់ក្នុងការបង្កើនចំណូលជាតិ ដើម្បីបំពេញតម្រូវការចំណាយសាធារណៈដែលកំពុងកើនឡើង។ ទោះបីការប្រមូលពន្ធត្រូវបានគ្រប់គ្រងដោយច្បាប់ក៏ដោយ ក៏ការយល់ដឹងនិងការទទួលខុសត្រូវរបស់អ្នកជាប់ពន្ធ គឺមានសារៈសំខាន់យ៉ាងច្បាស់។ ការយល់ដឹងពីសារៈសំខាន់នៃពន្ធនិងការបង់ពន្ធដោយស្មោះត្រង់ នឹងជួយអោយរដ្ឋអាចទទួលប្រាក់ចំណូលបានតាមគោលដៅ។

ដោយយោងទៅលើហេតុផលដ៏សំខាន់ទាំងនេះ ខ្ញុំបានសម្រេចជ្រើសយកប្រធានបទស្តីពី **"ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ"** ដើម្បីធ្វើជាផ្នែកស្រាវជ្រាវក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់នាងខ្ញុំ។

## ១.២ ចំណោទបញ្ហា នៃការស្រាវជ្រាវ

ជាទូទៅប្រភេទពន្ធ និងអ្នកជាប់ពន្ធមានលក្ខណៈផ្សេងៗគ្នា ទៅតាមប្រភេទអាជីវកម្មនីមួយៗ ដែលធ្វើប្រតិបត្តិការ ហេតុដូច្នេះទើបនាងខ្ញុំមានសំនួរមួយចំនួនដូចខាងក្រោម៖

១.តើអគ្គនាយកដ្ឋានពន្ធដារ បានកំណត់ពន្ធនៃអាករបំភ្លឺសាធារណៈយ៉ាងដូចម្តេច?

២.តើអគ្គនាយកដ្ឋានពន្ធដារ ធ្វើការប្រមូលអាករបំភ្លឺសាធារណៈតាមវិធីណា?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺបង្ហាញឱ្យស្គាល់អ្វីទៅជាអាករបំភ្លឺសាធារណៈ និង សិក្សាស្វែងយល់បន្ថែមអោយកាន់តែច្បាស់លាស់ទៅលើប្រភេទពន្ធមួយនេះ៖

- ប្រវត្តិនៃអគ្គនាយកដ្ឋានពន្ធដារកម្ពុជា
- វិធីសាស្ត្រក្នុងការគណនាអាករបំភ្លឺសាធារណៈ
- វិធីសាស្ត្រក្នុងការប្រមូលពន្ធប្រភេទនេះ
- រចនាសម្ព័ន្ធរបស់ពន្ធដារ
- តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែលកំណត់

ការសិក្សាស្រាវជ្រាវនេះ គឺសិក្សាទៅលើ «ដំណើរការនៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ» នៅអគារកែងមហាវិថីសហព័ន្ធរុស្សី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២ វិសាលភាព

តាមច្បាប់ស្ដីពីសារពើពន្ធ ពន្ធត្រូវបានបង្កើតឡើងយូរណាស់មកហើយ ហើយដោយមានពេលវេលាកំណត់ ការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពី ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ទើបនាងខ្ញុំធ្វើការស្រាវជ្រាវតែក្នុងឆ្នាំ ២០២៣ និង ២០២៤ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យដំណើរការនៃការសរសេរបាយការណ៍លើប្រធានបទ **«ដំណើរការនៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ»** ឱ្យបានជោគជ័យ នាងខ្ញុំបានធ្វើការស្រាវជ្រាវដូចខាងក្រោម៖

### ១.៥.១ ការប្រមូលទិន្នន័យចម្បង

- មុនដំបូងនាងខ្ញុំធ្វើការប្រមូលទិន្នន័យពីសៀវភៅពន្ធដារ ប្រកាសអន្តរក្រសួង ឬ គេហ៍ទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ បន្ទាប់មកនាងខ្ញុំប្រមូលពត៍មានពីមន្ត្រីជំនាញដោយធ្វើតាមរយៈការចុះសួរដោយផ្ទាល់ពីមន្ត្រី និង អ្នកគ្រប់គ្រង នៃអគ្គនាយកដ្ឋានពន្ធដារ។ បន្ទប់ពីការប្រមូលទិន្នន័យ និង ចុះសួរមន្ត្រីប្រហែលជា ៣ ទៅ ៤នាក់ នាងខ្ញុំបានប្រមូលទិន្នន័យនោះតាមលំដាប់លំដោយផ្សេងៗគ្នាទៅតាមសំណួរដែលនាងខ្ញុំបានដកស្រង់ និង ខ្លឹមសារអត្តន័យនៃប្រធានបទនីមួយៗ ដើម្បីងាយស្រួលឬជាមូលដ្ឋានគ្រឹះនៃការសរសេររបាយការណ៍ស្រាវជ្រាវអោយកាន់តែមានភាពងាយស្រួល។

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

- ការប្រមូលទិន្នន័យបន្ទាប់បន្សំ នាងខ្ញុំបានស្រាវជ្រាវតាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ( www.tax.gov.kh ) និង សៀវភៅពន្ធដារដែលបានចែងនិងចង់ក្រងជារាងរាល់ឆ្នាំ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

តាមការសិក្សាស្រាវជ្រាវនេះបានឆ្លុះបញ្ចាំងអំពីសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើន៖

- សម្រាប់សង្គម៖
  - បន្សល់ទុកនូវស្នាដៃ ដែលល្អមួយក្នុងសាកលវិទ្យាល័យវ៉ាន់ដា ហើយក៏ជាប្រភពឯកសារបន្ថែមមួយទៀត ដើម្បីស្វែងយល់ផ្នែកពន្ធដារ សម្រាប់ប្អូនៗជំនាន់ក្រោយ និងជនរួមជាតិទាំងឡាយ
- សម្រាប់អគ្គនាយកដ្ឋានពន្ធដារ៖
  - ពង្រឹងដល់ការប្រមូលពន្ធឱ្យបានកាន់តែល្អប្រសើរ
  - ផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព និងតម្លាភាព
  - ផ្តល់សេវាឱ្យប្រជាពលរដ្ឋប្រកបដោយភាពថ្លៃថ្នូរ និងការគោរព
- សម្រាប់អ្នកស្រាវជ្រាវ៖
  - យល់ដឹងពាក្យគន្លឹះមួយចំនួន ដែលប្រើប្រាស់ក្នុងផ្នែកពន្ធដារ
  - យល់ដឹងពីរចនាសម្ព័ន្ធនានានៃពន្ធដារ និងអគ្គនាយកដ្ឋានពន្ធដារ
  - បណ្តុះគំនិត និងបំពេញចំណេះវិជ្ជាបន្ថែមផ្នែកពន្ធដារ នៃព្រះរាជាណាចក្រកម្ពុជា

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការរៀបចំរចនាសម្ព័ន្ធស្រាវជ្រាវ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យមានការយល់ដឹងកាន់តែច្បាស់លាស់នៅលើចំណុចនីមួយៗ។ នៅក្នុងការស្រាវជ្រាវនេះ ការសិក្សាត្រូវបានធ្វើឡើងដោយការរាប់បញ្ចូលគ្រប់ចំណុចសំខាន់ៗដូចជា៖ សេចក្តីផ្តើមនៃការស្រាវជ្រាវ គោលដៅនៃការស្រាវជ្រាវ ការពិពណ៌នាពីវិធីសាស្រ្តដែលបានប្រើ ការកំណត់ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ព្រមទាំងបង្ហាញពីសារៈសំខាន់ និងរចនាសម្ព័ន្ធទូទៅរបស់ការស្រាវជ្រាវ។ ក្រៅពីនេះ ការស្រាវជ្រាវក៏បង្ហាញនូវសេចក្តីសន្និដ្ឋាន និង បានផ្តល់អនុសាសន៍ផ្សេងៗទៀតសម្រាប់ការអភិវឌ្ឍន៍បន្ថែម។

- **បន្ទាប់ពីការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់ នាងខ្ញុំបានបែងចែកចេញជា ៥ ជំណាក់កាលដូចខាងក្រោម៖**

- **ជំពូកទី១** សេចក្តីផ្តើម៖ បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណង មូលហេតុនៃការស្រាវជ្រាវចំណោទបញ្ហា ដែនកំណត់ និងវិសាលភាព ហេតុផលមួយចំនួនដែលបង្កើតឱ្យមាន ការសិក្សាស្រាវជ្រាវ។

- **ជំពូកទី២** រំលឹកទ្រឹស្តី ៖ បង្ហាញពីនិយមន័យ ប្រវត្តិទូទៅពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនិងការសិក្សាស្រាវជ្រាវ។
- **ជំពូកទី៣** លទ្ធផលនៃការស្រាវជ្រាវ ៖ បង្ហាញពីស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ គោលនយោបាយ ទស្សនៈវិស័យ និងបេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ។
- **ជំពូកទី៤** ការវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយ៖ វិភាគនិងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ។
- **ជំពូកទី៥** សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ៖ សន្និដ្ឋានទៅលើចំណុចទាំងអស់ ដែលនៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីកែលម្អ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ការប្រមូលអាករបំភ្លឺសាធារណៈ

## ២.១ លក្ខណៈទូទៅនៃការប្រមូលអាករបំភ្លឺសាធារណៈ

### ២.១.១ និយមន័យអាករបំភ្លឺសាធារណៈ

- **អាករសម្រាប់បំភ្លឺសាធារណៈ** (Public Lighting Tax) ត្រូវបានកំណត់តាមអត្រា ៥% លើសុរាមេរ័យ ឬថ្នាំជក់ និងត្រូវបង់តែម្ដងគត់នៅពេលផ្គត់ផ្គង់ដំបូងបន្ទាប់ពីផលិត ឬនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ឬនាំចូលផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់[1]។
- **អាករបំភ្លឺសាធារណៈ** (Public Lighting Tax ) យោងតាមប្រកាសក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២៤ អាករសម្រាប់បំភ្លឺសាធារណៈត្រូវកំណត់តាមអាត្រា ៥ (ប្រាំ)ភាគរយនៃមូលដ្ឋានគិតអាករ គឺជាថ្លៃផ្គត់ផ្គង់កត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម និង អាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង។ អាករសម្រាប់បំភ្លឺសាធារណៈត្រូវដល់កំណត់ និង ត្រូវបង់តែម្ដងគត់នៅពេលផ្គត់ផ្គង់ផលិតផលជាប់អាករដំបូងបន្ទាប់ពីផលិផល ឬនាំចូលក្នុងព្រះរាជណាចក្រកម្ពុជា[2]។
- **អាករបំភ្លឺសាធារណៈ** (Public Lighting Tax) គឺជាប្រភេទពន្ធប្រយោលដែលអ្នកប្រើប្រាស់មានកាតព្វកិច្ចត្រូវបង់ ហើយដែលត្រូវប្រមូលដោយអ្នកលក់ដើម្បីបង់ជូនរដ្ឋ។
- **អាករបំភ្លឺសាធារណៈ** (Public Lighting Tax) យោងតាមប្រកាសលេខ ៩៧៦ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាក្យ «**អាករសម្រាប់បំភ្លឺសាធារណៈ**» ត្រូវបានឱ្យនិយមន័យថា ជាអាករមួយប្រភេទដែលត្រូវកំណត់លើគ្រប់ដំណាក់កាល នៃការផ្គត់ផ្គង់សុរាមេរ័យ និងបារី បន្ទាប់ពីបាននាំចូល ឬ ផលិតផលិតផលជាប់អាករ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺសាធារណៈ ដែលពាក្យ «ផលិតផលជាប់អាករ» សំដៅដល់ សុរាមេរ័យ និង បារី [3]។

[1] អគ្គនាយកដ្ឋានពន្ធដារ | ខ្លឹមសារលម្អិត (tax.gov.kh) ស្ដីពីអាករសម្រាប់បំភ្លឺសាធារណៈ (Public Lighting Tax)

[2] d20440db-79d8-4a13-a420-714256acc3aa (tax.gov.kh) ស្ដីពីប្រកាសថ្មី ២០២៤ អាករសម្រាប់បំភ្លឺសាធារណៈ (Public Lighting Tax)

[3] យល់ដឹងផ្នែកច្បាប់៖ អាករសម្រាប់បំភ្លឺសាធារណៈ (freshnewsasia.com)

**២.១.២ ប្រវត្តិអាករបំភ្លឺសាធារណៈ**

អាករបំភ្លឺសាធារណៈត្រូវបានបង្កើតឡើងដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ គឺមាត្រា២៣។

**២.១.៣ ប្រភេទទំនិញដែលត្រូវជាប់អាករបំភ្លឺសាធារណៈ**

- **ផលិតផលជាប់អាករសំដៅដល់៖**
  - **សុរា**= គឺសំដៅដល់ផលិតផលគ្រប់ប្រភេទដែលមានជាតិអាល់គុលលើក លែងតែផលិតផលអាល់កុលដែលប្រើក្នុងវិស័យវេជ្ជសាស្ត្រ។
  - **មេរ៉ៃ**=គឺសំដៅដល់ ទឹកស្រវឹងដែលធ្វើឡើងដោយការត្រាំគ្រឿងផ្សំផ្សេងៗ ជាអាទិ៍ ស្រាបៀរ ឬភេសជ្ជៈមានជាតិស្រវឹងលើលែងតែទឹកត្នោតជូរនិងស្រាលដែលផលិតដោយមិនមានការកែច្នៃរក្សាគុណភាព ឬ វេចខ្ចប់តាមរូប ភាពសប្បិកម្មឬ ឧស្សាហកម្ម។
  - **ថ្នាំជក់** = គឺសំដៅដល់ ផលិតផលទាំងមូលឬមួយផ្នែកដែលផ្សំឡើងដោយ ស្លឹកថ្នាំជក់ ឬសារជាតុថ្នាំជក់ឬសារជាតុផ្សេងៗទៀតជាវត្ថុធាតុដើមដែលផលិត សម្រាប់យកទៅជាក់មានជាអាទិ៍ បារី បារីស៊ីហ្គា និង បារីអេឡិចត្រូនិកគ្រប់ប្រភេទ។

អាករបំភ្លឺសាធារណៈ (Public Lighting Tax) ត្រូវបានកំណត់តាមអាត្រា **៥%** នៅពេលនាំចូល និងលក់ចេញពីរោងចក្រ និងសំរាប់អាត្រា **(២០%*៥%)** គឺសំរាប់ដេប៉ូដែលចែកចាយលក់បន្តពីរោងចក្រ។

អាករបំភ្លឺសាធារណៈត្រូវបានកំណត់តាមអាត្រា **៥%**លើការផ្គត់ផ្គង់ទំនិញចេញពីរោងចក្រ និងការនាំចូលគ្រប់ដំណាក់កាលនូវ **ស្រា ស្រាបៀរ និងបារី**។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់ និងត្រឹមថ្ងៃទី ២៥ តាមប្រពន្ធ័ E-Filing។

- **អាករបំភ្លឺសាធារណៈ**

  (ប្រកាសលេខ ១៦៨ MEF.Prk.GDT ចុះថ្ងៃទី ២០ មីនា ២០២៤)

- អនុវត្តចាប់ពីថ្ងៃទី ១ មេសា ឆ្នាំ ២០២៤ ប្រកាសនេះត្រូវបានចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MoEF) ដើម្បីផ្តល់ការពន្យល់បន្ថែមលើច្បាប់និងនីតិវិធីសម្រាប់ការអនុវត្តពន្ធបំភ្លឺសាធារណៈ (Public Lighting Tax)។

ក្រោមនេះជាព័ត៌មានសំខាន់ៗដូចដែលបានលើកឡើងនៅក្នុងប្រកាស៖

| ធាតុ | ព័ត៌មានលម្អិត |
|---|---|
| **វិសាលភាព/ផលិតផលត្រូវចំណាយពន្ធ** | គ្របដណ្តប់លើផលិតផលទាំងអស់នៃអាល់កុល (លើកលែងតែផលិតផលអាល់កុលដែលប្រើប្រាស់ក្នុងវិស័យសុខាភិបាល) ស្រា ឬបារី។ |
| **អត្រាពន្ធ** | ៥% នៃមូលដ្ឋានពន្ធ |
| **មូលដ្ឋានពន្ធ** | តម្លៃតាមវិក្កយបត្រដែលមានគ្របដណ្តប់លើពន្ធផ្សេងទៀត លើកលែងតែ VAT និង PLT |

- **អាករបំភ្លឺសាធារណៈ** ត្រូវបានអនុវត្តតែលើការផ្គត់ផ្គង់ដំបូងប៉ុណ្ណោះនៃផលិតផលដែលត្រូវបង់ពន្ធបន្ទាប់ពីផលិត ឬនាំចូលនៅកម្ពុជា។
- ការផ្គត់ផ្គង់ផលិតផលដែលបានដំណើរការពីផលិតផលដែលត្រូវបានបង់ PLT ជាមុនហើយ ត្រូវបានចាត់ទុកជាការផ្គត់ផ្គង់ដំបូងបន្ទាប់ពីផលិត។
- បុគ្គលដែលទទួលសិទ្ធិផលិត ឬនាំចូលផលិតផលដែលត្រូវចំណាយពន្ធទៅកាន់បុគ្គលដែលត្រូវបង់ពន្ធត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោមៈ
- អោយដំណឹងទៅ GDT ដោយភ្ជាប់អត្តសញ្ញាប័ណ្ណនិងកិច្ចព្រមព្រៀងពាក់ព័ន្ធជាមួយបុគ្គលដែលត្រូវបង់ពន្ធ។
- ផ្អាកការផលិត ឬនាំចូលផលិតផលទៅបុគ្គលដែលត្រូវបង់ពន្ធបន្ទាប់ពីទទួលការជូនដំណឹងពី GDT។
- ត្រូវបានចាត់ទុកជាបុគ្គលដែលត្រូវបង់ពន្ធ និងត្រូវ **អាករបំភ្លឺសាធារណៈ** ក្នុងករណីមិនបំពេញតាមកាតព្វកិច្ចខាងលើ។
- កំណត់សំគាល់របស់យើង
  ប្រកាសថ្មីនេះផ្តល់ការពន្យល់បន្ថែមលើការកែប្រែការដាក់ពន្ធ **អាករបំភ្លឺសាធារណៈ**ដែលបានណែនាំនៅក្នុងច្បាប់ Law On Taxation ថ្មីនិងប្រកាសលេខ ២៨៦។ ទោះបីមានការកើនឡើងនៃអត្រា**អាករបំភ្លឺសាធារណៈ** (Public Lighting Tax) (**ពី 3% ទៅ 5%**)ក៏ដោយការអនុវត្ត **អាករបំភ្លឺសាធារណៈ** នេះបន្តឃើញច្បាប់ដាក់លាក់[4]។

## ២.២ ការកំណត់ពន្ធនៃអាករបំភ្លឺសាធារណៈ

### ២.២.១ និយមន័យពន្ធ

**ពន្ធ** គឺជាបន្ទុកសំខាន់ដែលអ្នកជាប់ពន្ធត្រូវមានចំពោះរដ្ឋ និងជាកាតព្វកិច្ចតាមច្បាប់ដែលប្រជាពលរដ្ឋគ្រប់រូបក្នុងសង្គមត្រូវអនុវត្ត។ ពន្ធ គឺជាកាតព្វកិច្ចសំខាន់ដែលអ្នកជាប់ពន្ធត្រូវបង់ទៅរដ្ឋ ដើម្បីឱ្យរដ្ឋមានសមត្ថភាពទទួលចំណូលសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសង្គម។ តាមច្បាប់ពន្ធដារឆ្នាំ ១៩៩៩ ពន្ធផ្ទាល់ត្រូវបានគេប្រមូលដោយផ្ទាល់ពីអ្នកជាប់ពន្ធ (taxpayer) ហើយពន្ធប្រយោលត្រូវបានកំណត់លើតម្លៃទំនិញ និងសេវាដែលប្រជាពលរដ្ឋប្រើប្រាស់។ **ពន្ធ** គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិកាជាតិ។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ជូនរដ្ឋ[5]។ **ពន្ធ** ជាឧបករណ៍របស់រដ្ឋាភិបាលដែលបានបង្កើតឡើងដើម្បីប្រមូលចំណូលចូលថវិកាជាតិសម្រាប់ចំណាយសេវាសាធារណៈ។

### ២.២.២ ប្រវត្តិពន្ធ

ក្នុងឆ្នាំ**១៩៥៣** ប្រព័ន្ធត្រូវបានបង្កើតឡើង ប៉ុន្តែក៏ត្រូវបានលុបចោលក្នុងរបបប៉ុលពត ក្នុងអំឡុងពេល **១៩៧៥ ដល់ ១៩៧៩** ។ ក្នុង ឆ្នាំ**១៩៨០-១៩៩៣** ដែលត្រូវបានហៅថាជា នាយកដ្ឋានពន្ធដារឧស្សាហពាណិជ្ជក្រសួងហិរញ្ញវត្ថុ បន្ទាប់មកទៀត នាយកដ្ឋានពន្ធដារ (អង្គភាពពន្ធដារ) ត្រូវបានគេហៅក្នុងឆ្នាំ

---

[4] Cambodia-Tax-Booklet_2023-2024.pdf (andersen.com)

[5] បណ្ណាល័យសាកលវិទ្យាល័យវ៉ាន់ដា

១៩៩៣-២០០៨ ។ នៅក្នុងឆ្នាំ២០០៨ ដ៏ដែលនេះ នាយកដ្ឋានពន្ធដារ (អង្គភាពពន្ធដារ) ត្រូវបានដំឡើងជាអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លើសពីនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀតដើម្បីយកអនុវត្ត និងមានការបែងចែកច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់។ ផ្អែកទៅលើមាត្រា៤ នៃច្បាប់សារពន្ធបានបង្កើតឡើងនូវការកំណត់របបពន្ធជាបីប្រភេទ៖ គឺរបបពិត របបម៉ៅការ របបបំព្រួញ ក៏ប៉ុន្តែបទប្បញ្ញត្តិស្តីពីរបបបំព្រួញមានចែងក្នុងក្រដាសមួយដាច់ដោយឡែក។ ប៉ុន្តែនៅពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាយើងមានតែរបបពិត(ស្វ័យប្រកាស)តែប៉ុណ្ណោះ។ ការអនុវត្ត និងការកំណត់នៃរបបពិតរបស់សហគ្រាសដោយផ្អែកទៅលើទ្រង់ទ្រាយគតិយុត្តិនៃកម្រិតផលរបរប្រចាំឆ្នាំ និងប្រភេទសកម្មភាពអាជីវកម្ម។

**២.២.៣ ប្រភេទពន្ធ**

ពន្ធ គឺជាចំណូលចរន្តដ៏សំខាន់របស់រដ្ឋ សម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗ។ នៅកម្ពុជាបច្ចុប្បន្នបានកំណត់នូវពន្ធចំនួន ១៨ប្រភេទ ដែលតម្រូវឱ្យប្រជាពលរដ្ឋ ឬអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការបង់ជូនរដ្ឋ។ ប្រភេទពន្ធទាំងនោះរួមមាន៖

| **ពន្ធលើប្រាក់ចំណេញ** | **ពន្ធលើប្រាក់បៀវត្ស** | **អាករលើផលរបរ** | **ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ** |
|---|---|---|---|
| **អាករពិសេសលើទំនិញ និងសេវាមួយចំនួន** | ពន្ធអប្បបរមា | ពន្ធកាត់ទុក | ពន្ធប៉ាតង់ |
| **ពន្ធប្រថាប់ត្រា** | ពន្ធលើអចលនទ្រព្យ | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | ពន្ធសត្តឃាត |
| **អាករស្នាក់នៅ** | អាករបំភ្លឺសាធារណៈ | ពន្ធលើឈ្នួលផ្ទះ និងដី | ពន្ធតែមប្រ៊ី |
| **ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ៦។** | ពន្ធលើស្លាកសញ្ញា | | |

6 https://www.tax.gov.kh

**២.២.៤ ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ**

មាត្រាទី១០១ នៃច្បាប់ស្តីពីសារពើពន្ធ

«បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនេះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច»។ «ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងកំឡុង១៥ថ្ងៃ ក្រោយពីផ្លាស់ប្តូរឈ្មោះអាស័យដ្ឋានទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស»។

មាត្រា៣(ថ្មី)នៃច្បាប់ស្តីពីសារពើពន្ធ

«**នីតិបុគ្គល**» សំដៅដល់សហគ្រាស ឬអង្គភាពនានាដែលប្រកបអាជីវកម្ម ទោះបីបាន ឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។ ពាក្យ«**នីតិបុគ្គល**»រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាល អង្គការ សាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកប្រាក់ចំណេញ។ ចំពោះបុគ្គលអនិវាសនជន ពាក្យ«**នីតិបុគ្គល**»សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា។ ពាក្យ«**នីតិបុគ្គល**»ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនអាជីវកម្ម ឬសហគ្រាសឯកបុគ្គល។

**ប្រកាសលេខ ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការចុះបញ្ជីពន្ធដារ**

«**អាជីវកម្ម**» សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅ ទាញយកប្រាក់ចំណូលពីការផលិត និងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួល ឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងៗទៀត។

**ប្រកាសលេខ០២៥ សហវ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកែប្រែប្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**[7]

- **លក្ខខណ្ឌកំណត់ជាមួយអ្នកជាប់ពន្ធតូច**

  ចំណាត់ថ្នាក់អ្នកជាប់ពន្ធ ត្រូវបានកំណត់តាម២ករណីដោយឡែកពីគ្នា ចំពោះសហគ្រាសដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

  **ក.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

  ការកំណត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមានវិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងពាណិជ្ជកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធតូច ប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

  - រំពឹងថា មានផលរបរក្នុងរយៈពេល៣ខែ ជាប់គ្នាខាងមុខ ចាប់ពី៦០លានរៀលឡើងទៅ ឬ
  - មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ១០០០លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម
  - មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១៦០០លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ

[7] អគ្គនាយកដ្ឋានពន្ធដារ | ខ្លឹមសារលម្អិត (tax.gov.kh) លក្ខខណ្ឌកំណត់ជាអ្នកជាប់

- មានផលរបរក្នុងរយៈពេល៣ខែ ជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី ៦០លាន រៀលឡើងទៅ ឬ
- ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវារួមទាំងភាស៊ី

**ខ. ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម**

ក្នុងករណីផលរបរដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែង ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធត្រូវបានធ្វើឡើងវិញដោយផ្អែកលើតម្លៃទ្រព្យសកម្មដែលប្រើប្រាស់ក្នុងអាជីវកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធតូចប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំ ២០០លានរៀលដល់ ១០០០លាន រៀលសម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម
- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំ ២០០លានរៀល ដល់ ២០០០លានរៀល សម្រាប់វិស័យ ឧស្សាហកម្ម។

- **លក្ខខណ្ឌកំណត់ជាអ្នកជាប់ពន្ធមធ្យម**

**ក.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

ការកំណត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងពាណិជ្ជកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធមធ្យម ប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- ផលរបរប្រចាំឆ្នាំលើសពី ១០០០ លានរៀល ដល់ ៤០០០ លានរៀល សម្រាប់វិស័យកសិកម្ម ឬ
- ផលរបរប្រចាំឆ្នាំលើសពី ១០០០ លានរៀល ដល់ ៦០០០ លានរៀល សម្រាប់វិស័យសេវាកម្ម និង ពាណិជ្ជកម្ម ឬ
- ផលរបរប្រចាំឆ្នាំលើសពី ១៦០០ លានរៀល ដល់ ៨០០០លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ ជាសហគ្រាស ដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង ឬ
- ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនានា ឬគម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ ឬ
- បេសកកម្មទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ឬគម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ។

**ខ.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម**

ក្នុងករណីផលរបរដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែង ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធត្រូវបានធ្វើឡើងវិញដោយផ្អែកលើតម្លៃទ្រព្យសកម្មដែលប្រើប្រាស់ក្នុងអាជីវកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធមធ្យម ប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំ ១០០០ លានរៀល ដល់ ២០០០ លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬ
- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំ ២០០០ លានរៀល ដល់ ៤០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម។

- **លក្ខខណ្ឌកំណត់ជាអ្នកជាប់ពន្ធធំ**

**ក.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

ការកំណត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងពាណិជ្ជកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធធំ ប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- ផលរបរប្រចាំឆ្នាំលើសពី ៤ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម ឬ
- ផលរបរប្រចាំឆ្នាំលើសពី ៦ ០០០ លានរៀល សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម ឬ
- ផលរបរប្រចាំឆ្នាំលើសពី ៨ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ
- បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ
- សហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។

**ខ.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម**

ក្នុងករណីផលរបរដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែង ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធត្រូវបានធ្វើឡើងវិញដោយផ្អែកលើតម្លៃទ្រព្យសកម្មដែលប្រើប្រាស់ក្នុងអាជីវកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធធំ ប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ២ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម
- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ៤ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម។

**តារាងជាឯកសារតម្រូវតាមប្រភេទពន្ធដែលចុះបញ្ជី៖**

| ឯកសារតម្រូវ | |
|---|---|
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់ SOI) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព |
| ៣ | រូបថតបច្ចុប្បន្នមិនលើសពី ០៣ខែ ទំហំ ៣៤ x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន ២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬតំណាងសមាគម ឬអង្គភាពនានា |
| ៤ | បណ្ណកម្មសិទ្ធកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងអាជីវកម្ម |
| ឯកសារត្រូវភ្ជាប់បើមាន | |
| ១ | លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |

| | |
|---|---|
| ២ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៣ | អាជ្ញាបណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច |
| ➢ **សម្រាប់អ្នកជាប់ពន្ធមធ្យម-ធំ** | |
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់១០១) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| ៣ | លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល |
| ៤ | ព័ត៌មានគណនីធនាគារសម្រាប់សកម្មភាពអាជីវកម្មដោយឡែក ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅធនាគារ ដែរចេញដោយធនាគារ |
| ៥ | អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព |
| ៦ | រូបថតបច្ចុប្បន្នមិនលើសពី ០៣ខែ ទំហំ៣៥ x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌សចំនួន០២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬតំណាងសមាគម ឬអង្គភាពនានា |
| ៧ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៨ | អាជ្ញាបណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច |

## ២.៣ ការប្រមូលអាករបំភ្លឺសាធារណៈ

### ២.៣.១ និយមន័យអាករ

អាករ គឺសំដៅដល់កាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវបង់ (សាច់ប្រាក់ ឬវត្ថុ) ជូនរដ្ឋតាមច្បាប់កំណត់ ដោយប្រយោល ហើយពន្ធនេះត្រូវប្រមូលពីអ្នកប្រើប្រាស់ចុងក្រោយតាមរយៈអ្នកផ្គត់ផ្គង់[8]។

និយាយឱ្យងាយយល់ អាករ មានន័យថាជាពន្ធប្រយោល ឬបន្ទុកប្រយោល ឬកាតព្វកិច្ចប្រយោល ដែលតម្រូវឱ្យបង់ដោយប្រយោលពីអ្នកជាប់ពន្ធ។

### ២.៣.២ ប្រភពនៃអាករ

អាករបំភ្លឺសាធារណៈត្រូវបានបង្កើតឡើងដោយច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ គឺមាត្រា២៣។

អាករលើតម្លៃបន្ថែម ដែលអតិថិជនបានទូទាត់តាមរយៈការទិញ ប្រើប្រាស់ ឬទូទាត់លើថ្លៃសេវាកម្ម

ឬផលិតផលនានាគឺជាកាតព្វកិច្ចរបស់ ក្រុមហ៊ុន សហគ្រាស អាជីវកម្មនានាដែលចុះបញ្ជីស្របច្បាប់ត្រូវបង់ជូនរដ្ឋជំនួសអតិថិជន។

[8] https://www.tax.gov.kh

អាករលើការស្នាក់នៅ គឺជាប្រភេទពន្ធប្រយោលដែលគិតលើតម្លៃសរុបនៃការជួលកន្លែងស្នាក់នៅដែលអ្នកប្រើប្រាស់សេវាស្នាក់នៅជាប់កាតព្វកិច្ចត្រូវបង់ និងដែលទទួលកាត់ទុកដោយអ្នកផ្គត់ផ្គង់ ដើម្បីបង់ជូនរដ្ឋជាបន្តបន្ទាប់នាពេលក្រោយទៀត។ មូលដ្ឋានគិតជាអាករ គឺជាថ្លៃបន្ទប់ស្នាក់នៅក្នុងសណ្ឋាគារដោយរួមបញ្ចូនទាំងពន្ធ-អាករ និងបន្ទុកសេវាផ្សេងៗប៉ុន្តែត្រូវលើកលែងអាករលើតម្លៃបន្ថែម និងអាករស្នាក់នៅខ្លួនឯង។

អាករលើផលរបរ គឺជាប្រភេទពន្ធប្រយោល ដែលត្រូវបានយកពន្ធពីសកម្មភាពសេដ្ឋកិច្ចផ្សេងៗដូចជាពាណិជ្ជកម្ម ផលិតកម្ម អាជីវកម្ម និងសេវាកម្ម។ អាករលើផលរបរប្រមូលពីអ្នកប្រើប្រាស់ និងបង់ជូនរដ្ឋដោយអ្នកលក់។

**២.៣.៣ ការគណនាអាករសម្រាប់បំភ្លឺសាធារណៈ**

- ចំពោះបុគ្គលជាប់អាករតាមរបបស្វ័យប្រកាស

| |
|---|
| អាករបំភ្លឺសាធារណៈត្រូវបង់ = មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ x អាត្រា |

| |
|---|
| មូលដ្ឋានគិតVAT = មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ / ១.១ |

| |
|---|
| មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ / ១.០៥ |

**ឧទាហរណ៍៖** ភោជនីយដ្ឋានមួយ មានចំណូលរួមបញ្ចូលទាំងអាករនានាក្នុងមួយខែ កញ្ញា ឆ្នាំ២០២៤ ចំណូលពីសេវាកម្ម ៥៥,000,000រៀល និងចំណូលពីការលក់ស្រាបៀរមានចំនួន ១១,000,000រៀល (ភោជនីយដ្ឋានមិនមានការប្រគុំតន្ត្រីទេ)ដោយដឹងថាអាករលើធាតុចូលដែលអនុញ្ញាតជាឥណទានចំនួន ៥,000,000រៀល។ តើភោជនីយដ្ឋានត្រូវបង់ពន្ធអ្វីខ្លះ?

**ចម្លើយ៖** ភោជនីយដ្ឋានត្រូវបង់ប្រាក់អាករដូចខាងក្រោម៖

| | | |
|---|---|---|
| មូលដ្ឋានគិតអាករលើតម្លៃបន្ថែម | = (៥៥,000,000+១១,000,000)រៀល/១,១ | **=៦0,000,000រៀល** |
| អាករលើធាតុចេញ | =៦0,000,000រៀល x១0% | **=៦,000,000រៀល** |
| អាករលើតម្លៃបន្ថែមត្រូវបង់ | =៦,000,000រៀល-៥,000,000រៀល | **=១,000,000រៀល** |

**គណនាអាករសម្រាប់បំភ្លឺសាធារណៈ៖**

| | | |
|---|---|---|
| ផលរបរមិនរួមអតប | =១១,000,000រៀល/១,១ | **=១0,000,000រៀល** |
| មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ | = (១0,000,000រៀល x ២0%)/១,00៦ | **=១,៩៨៨,0៧២រៀល** |
| អាករសម្រាប់បំភ្លឺសាធារណៈ | = ១,៩៨៨,0៧២រៀល x ៥% | **=៩៩,៤0៤រៀល** |
| ប្រាក់រំដោះពន្ធលើប្រាក់ចំណូល | = ៦0,000,000រៀល x ១% | **=៦00,000រៀល** |

ដូច្នេះសហគ្រាសត្រូវបង់៖

| | |
|---|---|
| ប្រាក់រំដោះពន្ធលើប្រាក់ចំណូល | =៦០០,០០០រៀល |
| អាករលើតម្លៃបន្ថែម | =១,០០០,០០០រៀល |
| អាករសម្រាប់បំភ្លឺសាធារណៈ | =៩៩,៤០៤រៀល |

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិអគ្គនាយកដ្ឋានពន្ធដារ



### ៣.១.១ ប្រវត្តិសង្ខេបនៃអគ្គនាយកដ្ឋានពន្ធដារ

ក្នុងឆ្នាំ**១៩៥៣** ប្រព័ន្ធត្រូវបានបង្កើតឡើង ប៉ុន្តែក៏ត្រូវបានលុបចោលក្នុងរបបប៉ុលពត ក្នុងអំឡុងពេល **១៩៧៥ ដល់ ១៩៧៩** ។ ក្នុង ឆ្នាំ**១៩៨០-១៩៩៣** ដែលត្រូវបានហៅថាជា នាយកដ្ឋានពន្ធដារឧស្សាហពាណិជ្ជក្រសួងហិរញ្ញវត្ថុ បន្ទាប់មកទៀត នាយកដ្ឋានពន្ធដារ (អង្គភាពពន្ធដារ) ត្រូវបានគេហៅក្នុងឆ្នាំ

១៩៩៣-២០០៨ ។ នៅក្នុងឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន នាយកដ្ឋានពន្ធដារ (អង្គភាពពន្ធដារ) ត្រូវបានដំឡើងជាអគ្គនាយកដ្ឋានពន្ធដារដែលស្ថិតនៅក្រោម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាលទទួលបន្ទុកគ្រប់គ្រងនិងប្រមូលចំណូលពន្ធផ្ទៃក្នុង ស្របតាមច្បាប់ស្តីពីសារពើពន្ធ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ថវិកាជាតិ ប្រកបដោយប្រសិទ្ធភាព តម្លាភាព ការទទួលខុសត្រូវ និង វិជ្ជាជីវៈខ្ពស់ ស្របទៅតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល។

**៣.១.២ ទស្សនវិស័យ**

អគ្គនាយកដ្ឋានពន្ធដារ ជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

**៣.១.៣ បេសកកម្ម**

អគ្គនាយកដ្ឋានពន្ធដារ ផ្តល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្ត ឈានទៅសម្រេចបាននូវការអភិវឌ្ឍនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**៣.១.៤ គុណតម្លៃ**

អគ្គនាយកដ្ឋានពន្ធដារ បំពេញបេសកកម្ម និងធ្វើប្រតិបត្តិការរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគុណតម្លៃដូចខាងក្រោម៖

- **ការអនុវត្ត៖** អនុវត្តវិធាននៃច្បាប់ គាំទ្រប្រជាពលរដ្ឋដែលប្រព្រឹត្តត្រឹមត្រូវ តាមច្បាប់ និងតឹងរ៉ឹងចំពោះជនដែលមិនអនុលោមតាមច្បាប់
- **វិជ្ជាជីវៈ៖** ប្តេជ្ញាចិត្តប្រើវិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមាន ភាពសាមញ្ញ និងងាយស្រួល
- **ស័ក្តិសិទ្ធិភាព៖** ប្រើប្រាស់ធនធានឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព
- **សុចរិតភាព៖** ផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព និងតម្លាភាព
- **គារវភាព៖** ផ្តល់សេវាឱ្យប្រជាពលរដ្ឋប្រកបដោយភាពថ្លៃថ្នូរ និងការគោរព
- **ភាពបត់បែន៖** ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន។

**៣.១.៥ និមិត្តសញ្ញា និង រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ**


ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
Ministry of Economy and Finance
អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation

១ រចនាសម្ព័ន្ធនៃការគ្រប់គ្រង

- **ឯកឧត្តម គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ
- **ឯកឧត្តម អ៊ុំ សីហា** អគ្គនាយករង
- **ឯកឧត្តម ជាប ជាតុច** អគ្គនាយករង
- **ឯកឧត្តម មិញ បានកុសល** អគ្គនាយករង
- **ឯកឧត្តម កែន សម្បត្តិ** អគ្គនាយករង
- **ឯកឧត្តម ហេង សុខណាង** អគ្គនាយករង
- **លោកជំទាវ ប៊ុន ធារី** អគ្គនាយករង
- **ឯកឧត្តម រ៉ុត មុនី** អគ្គនាយករង
- **លោក លឹម ជីលុច** អគ្គនាយករង
- **ឯកឧត្តម លឹម ហ៊ុយជីវ** អគ្គនាយករង

## ៣.២ ការកំណត់ពន្ធនៃអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ ការបង្កើតអាករបំភ្លឺសាធារណៈ

យោងតាមច្បាប់ពន្ធដារស្តីពីអាករបំភ្លឺសាធារណៈ (Public Lighting Tax) ពន្ធនេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ តាមមាត្រា២៣។ ប៉ុន្តែ មាត្រា២៣នេះត្រូវបានប្តូរទៅជាមាត្រា២៣ថ្មីដោយធ្វើវិសោធនកម្មលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០២ ចំពោះតម្លៃស្រា ស្រាបៀរ និងបារីដែលលក់នៅក្នុងដែនដីខេត្តក្រុង។ ដូចនេះមាត្រាទី២៣នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ត្រូវបានទុកនិរាករណ៍។ បន្ថែមពីនេះទៅទៀត ប្រកាសអន្តរក្រសួងលេខ១៧៥ សហវ. ពដ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០២២ ស្តីពីការគ្រប់គ្រងនិងការប្រមូលអាករបំភ្លឺសាធារណៈ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើនិយ័តកម្មលើការអនុវត្ត និងការប្រមូលអាករបំភ្លឺសាធារណៈ។ ជាពិសេសទៅទៀត យើងសង្កេតឃើញថានៅក្នុងឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានចេញប្រកាសថ្មីនិយ័តកម្មស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ ដែលមានចែងនៅក្នុងប្រកាសអន្តរក្រសួងលេខ១៩៨ សហវ.ប្រក.អពដ ចុះនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤។

បុគ្គលដែលធ្វើការផ្គត់ផ្គង់ស្រា ស្រាបៀរ និង បារី គឺជាបុគ្គលជាប់អាករបំភ្លឺសាធារណៈ និងទទួលខុសត្រូវចំពោះអាករនេះ។ បុគ្គលជាប់អាករត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់អាករសម្រាប់បំភ្លឺសាធារណៈដែលត្រូវបានអនុវត្តតែលើការផ្គត់ផ្គង់ដំបូងប៉ុណ្ណោះនៃផលិតផលដែលត្រូវបង់ពន្ធបន្ទាប់ពីផលិត ឬនាំចូលនៅកម្ពុជា។

### ៣.២.២ បុគ្គលជាប់អាករ

- បុគ្គលជាប់អាករបំភ្លឺសាធារណៈសំដៅដល់(អ្នកផលិត និង អ្នកនាំចូលផលិតផលជាប់អាករ ហើយធ្វើការផ្គត់ផ្គង់នៅក្នុងព្រះរាជណាចក្រកម្ពុជា)
  - អ្នកផលិត = គឺសំដៅដល់ ម្ចាស់ផលិតផល ដែលផលិត ផលិតផលជាប់អាករដោយ ខ្លួនឯក ឬដែលជួលបុគ្គលដទៃទៀតអោយផលិត ផលិតផលជាប់អាករអោយខ្លួន។
  - អ្នកនាំចូល = គឺសំដៅដល់ ម្ចាស់ផលិតផលដែលនាំចូលផលិតផលជាប់អាករដោយខ្លួនឯង ឬ ដែលប្រគល់សិទ្ធិអោយបុគ្គលដទៃទៀតនាំចូលផលិតផលជាប់អាករអោយខ្លួន។

បុគ្គលដែលធ្វើការផ្គត់ផ្គង់សុរាមេរ៉ៃ និងបារី គឺជាបុគ្គលជាប់អាករបំភ្លឺសាធារណៈ និងទទួលខុសត្រូវចំពោះអាករនេះ។ បុគ្គលជាប់អាករ (taxpayer) ត្រូវប្រមូលអាករបំភ្លឺសាធារណៈ (Public Lighting Tax) នេះពីអតិថិជនរបស់ខ្លួន និងយកប្រាក់អាករនេះ ទៅបង់ជូនការិយាល័យគ្រប់គ្រងប្រមូលពន្ធតាមរបបពិតចំពោះបុគ្គលជាប់អាករតាមរបបពិត (real regime taxpayer) ឬសាខាពន្ធដារ ខេត្ត-ក្រុង ។

បុគ្គលជាប់អាករតាមរបបពិត Real Regime Taxpayer ត្រូវដាក់លិខិតប្រចាំខែ (Monthly Tax Declaration) យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ហើយត្រូវបង់ប្រាក់អាករនេះទៅតាមចំនួនដែលបានប្រកាស នៅពេលដាក់លិខិតប្រកាសនេះ។ ដូចនេះអាករបំភ្លឺសាធារណៈ (Public Lighting Tax) គឺជាពន្ធប្រចាំខែ (monthly tax) ។

### ៣.២.៣ ទំនិញជាប់អាករ

- បុគ្គលជាប់អាករបំភ្លឺសាធារណៈសំដៅដល់(អ្នកផលិត និង អ្នកនាំចូលផលិតផលជាប់អាករ ហើយធ្វើការផ្គត់ផ្គង់នៅក្នុងព្រះរាជណាចក្រកម្ពុជា)
  - អ្នកផលិត = គឺសំដៅដល់ ម្ចាស់ផលិតផល ដែលផលិត ផលិតផលជាប់អាករដោយ ខ្លួនឯក ឬដែលជួលបុគ្គលដទៃទៀតអោយផលិត ផលិតផលជាប់អាករអោយខ្លួន។
  - អ្នកនាំចូល = គឺសំដៅដល់ ម្ចាស់ផលិតផលដែលនាំចូលផលិតផលជាប់អាករដោយខ្លួនឯង ឬ ដែលប្រគល់សិទ្ធិអោយបុគ្គលដទៃទៀតនាំចូលផលិតផលជាប់អាករអោយខ្លួន។

យោងតាមប្រកាស២ នៃប្រកាសលេខ ១៧៥ សហវ.ពដ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រង និងការប្រមូលអាករបំភ្លឺសាធារណៈ ត្រូវបានចាត់ទុកជាសុរាមេរ៉ៃ និងបារី រួមមាន៖

- ស្រាបៀរ
- ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរមានបន្ថែមជាតិសុរា

- ស្រាវែមុត និងស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតផ្សំពីរុក្ខជាតិ និងសារជាតិក្រអូប
- ភេសជ្ជៈមេរ៍យផ្សេងៗ លើកលែងតែទឹកត្នោតជូរ និងស្រាស
- អាល់កុលអេទីលិកសុទ្ធមានកម្រិតជាតិសុរាក្នុងឯកតាចំណុះពី៨០៥ នៃចំណុះ ឬលើសពីនេះ និងអាល់កុល អេទីលិក ហើយនិងភេសជ្ជៈមានជាតិសុរាដែលបាត់បង់កម្រិតសុរាដើមរបស់វា
- អាល់កុលអេទីលិកបាត់បង់ជាតុសុទ្ធដែលមានកម្រិតជាតិសុរាក្នុងឯកតាសំណុះទី៨០៥ នៃចំណុះ និងភេសជ្ជៈមានជាតិស្រវឹងផ្សេងៗទៀតការរៀបចំកែច្នៃសុរាផ្សំក្នុងប្រភេទដែលប្រើសម្រាប់ផលិតភេសជ្ជៈ បារី បារីស៊ីហ្គា គ្រប់ប្រភេទ។

**៣.២.៤ ទំនិញជាប់អាករ**

**ក. វិធានទូទៅ នៃការគណនាអាករត្រូវបង់**

តាមមាត្រា ២៣ថ្មី នៃច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០២ អាករបំភ្លឺសាធារណៈត្រូវបានប្រមូលលើតម្លៃសុរាមេរ៍យ និងបារី ដែលលក់ក្នុងមណ្ឌលដែនដីខេត្ត-ក្រុងនីមួយៗ។

ដើម្បីគណនាប្រាក់អាករត្រូវបង់ បុគ្គលជាប់អាករ (taxpayer) ត្រូវធ្វើការបែងចែកឱ្យបានរវាងផលរបរដែលបានមកពីការផ្គត់ផ្គង់សុរាមេរ៍យ និងបារី ជាប់អាករ និងផលរបរបានមកពីការផ្គត់ផ្គង់ទំនិញ ឬសេវាដទៃទៀត។ ក្នុងករណីដែលបុគ្គលជាប់អាករតាមរបបម៉ៅការ (estimated regime taxpayer) ពុំអាចធ្វើការបែងចែកផលរបរបានមន្ត្រីពន្ធត្រូវពិភាក្សាជាមួយបុគ្គលជាប់អាករ ដើម្បីកំណត់សមាមាត្រនៃផលរបរបានមកពីការផ្គត់ផ្គង់ សុរាមេរ៍យ និងបារីជាប់អាករ។ សមាមាត្រនេះ ត្រូវពិនិត្យ និងសម្រេចដោយប្រធានសាខាពន្ធដារខេត្ត-ក្រុង។

អាករនេះត្រូវកំណត់នៅគ្រប់ដំណាក់កាលផ្គត់ផ្គង់ និងត្រូវអនុវត្តលើតម្លៃផ្គត់ផ្គង់ផលិតផលជាប់អាកររួមបញ្ចូលទាំងពន្ធអាករនានា លើកលែងតែអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង និងអាករលើតម្លៃបន្ថែមចំពោះបុគ្គលជាប់អាករតាមរបបពិត (ស្វ័យប្រកាស) (real regime taxpayer) ។ ដូចនេះមូលដ្ឋានគិតអាករ (tax base) គឺជាចំនួនផលរបរ ដែលអនុញ្ញាតឱ្យកាត់ចេញនូវអាករបំភ្លឺសាធារណៈ (Public Lighting Tax) ខ្លួនឯង និងអាករលើតម្លៃបន្ថែម (value added tax) ឬអាករលើផលរបរ (turnover tax)។

**ខ. ចំពោះបុគ្គលជាប់អាករតាមរបបស្វ័យប្រកាស**

| |
|---|
| អាករបំភ្លឺសាធារណៈត្រូវបង់ = មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ x អាត្រា |

| |
|---|
| មូលដ្ឋានគិតVAT = មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ / ១.១ |

| |
|---|
| មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ / ១.០៥ |

ឧទាហរណ៍ ៖ អ្នកផ្គត់ផ្គង់សុរាមេរ៉យ និងបារីទទួលបានផលរបរប្រចាំខែរួមមាន សុរាមេរ៉យចំនួន ១៥០រៀល និងបារីចំនួន ១០០រៀល។

- មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = ២៥០រៀល / ១.១ = ២២៧.២៧រៀល
- មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = ២២៧.២៧រៀល / ១.០៥ = ២១៦.៤៤រៀល
- អាករត្រូវបង់ = ២១៦.៤៤រៀល x ៥% = ១០.៨២រៀល

## ៣.៣ វិធី នៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

កាលពីមុនអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ធ្វើការបង់ប្រាក់ពន្ធ និងស្នើសុំទម្រង់លិខិតប្រកាសពន្ធ នៅតាមសាខាពន្ធដារខណ្ឌរៀងៗខ្លួន។ ប៉ុន្តែដោយមានភាពលំបាកពេកសម្រាប់មន្ត្រីពន្ធក៏ដូចជាអ្នកជាប់ពន្ធរាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់មួយចំនួនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយធ្វើការផ្លាស់ប្តូរ នីតិវិធីក្នុងការប្រមូលពន្ធ-អាករ និងការដាក់លិខិតប្រកាសពន្ធផ្សេងឱ្យមានលក្ខណៈទំនើប និងងាយស្រួលសម្រាប់អ្នកជាប់ពន្ធនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

### ៣.៣.១ ការប្រមូលប្រាក់អាករ

ការប្រមូលប្រាក់អាករនាពេលបច្ចុប្បន្ន ក៏ដូចជាការប្រមូលប្រាក់ពន្ធដទៃទៀតដែរ គឺអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការគណនាពន្ធដោយខ្លួនឯង បំពេញលិខិតប្រកាសបង់ពន្ធ ហើយធ្វើការបង់នៅតាមកុងគណនីធនាគាររបស់ពន្ធដារទៅតាមសាខាខណ្ឌរបស់ក្រុមហ៊ុនដែលតាំងទីលំនៅ

- **ជម្រើសទី១**

ដើម្បីភាពងាយស្រួលនិងឆាប់រហ័សទាន់ចិត្តអ្នកជាប់ពន្ធអាចចូលទៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ដោយស្វែងរកពាក្យ «ការប្រកាសបង់ប្រាក់ពន្ធ» ហើយអនុវត្តតាមលំដាប់លំដោយ និងការណែនាំនៅក្នុងគេហទំព័រដូចខាងក្រោម៖

- បំពេញការិយាបរិច្ឆេទ នៃការបង់ពន្ធរបស់ខ្លួន(ខែ ឆ្នាំ ពីថ្ងៃ ដល់ថ្ងៃ)ឧទាហរណ៍៖ ខែកក្កដា ឆ្នាំ ២០១៩ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃ៣១
- ជ្រើសរើសប្រភេទពន្ធ និងបំពេញចំនួនទឹកប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទពន្ធនីមួយៗដូចក្នុងលិខិតប្រកាស
- ជ្រើសរើសកម្រៃសេវាផ្សេងៗ និងបំពេញទឹកប្រាក់ដែលត្រូវបង់ (ប្រសិនបើមាន)។
- ត្រូវបំពេញចំនួនទំព័រនៃទម្រង់លិខិតប្រកាសនីមួយៗ
- នៅពេលបំពេញរួចត្រូវបោះពុម្ព (Print) លិខិតស្នើសុំបង់ប្រាក់ពន្ធចេញពីប្រព័ន្ធគ្រប់គ្រងដែលមាន Barcode សម្រាប់សម្គាល់ចេញពីម៉ាស៊ីនបោះពុម្ព (Print) ហើយអ្នកជាប់ពន្ធអាចយកលិខិតនេះទៅបង់ពន្ធ នៅធនាគារណាមួយដែលទទួលបន្ទុកទទួលប្រាក់បង់ពន្ធ។

- **ជម្រើសទី២**

ក្នុងករណីអ្នកជាប់ពន្ធមិនសូវចេះប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធ Online អ្នកជាប់ពន្ធត្រូវទៅធនាគារណាមួយទទួលបន្ទុកទទួលប្រាក់បង់ពន្ធ ហើយអនុវត្តតាមជំហាននីមួយៗដូចខាងក្រោម៖

- បំពេញទម្រង់បង់ប្រាក់ពន្ធ (From101) នូវប្រភេទពន្ធ និងចំនួនទឹកប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទពន្ធនីមួយៗដូចក្នុងលិខិតប្រកាស
- ដាក់ទម្រង់បង់ប្រាក់ពន្ធ (From101) ដែលបំពេញរួចជូនមន្ត្រីធនាគារដើម្បីបង់ប្រាក់ពន្ធ។ ធនាគារដែលទទួលខុសត្រូវក្នុងការប្រមូលពន្ធជូនរដ្ឋមានដូចជា៖ ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ធនាគារវឌ្ឍនៈ ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ធនាគារកម្ពុជាសាធារណៈ ធនាគារស្ថាបនា ល។

ឧទាហរណ៍តារាង ៖ លេខគណនីរបស់ធនាគារមួយចំនួន ៖

| ធនាគារ | លេខគណនី | ប្រភេទឈ្មោះគណនី |
|---|---|---|
| អេស៊ីលីដា ភីអិលស៊ី | 2900-01677788-1-8 | ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ |
| | 2900-01677777-1-7 | ប្រាក់ពន្ធលើអចលទ្រព្យ |
| | 2900-01655555-1-5 | ប្រាក់ទោសទណ្ឌ |
| កាណាឌីយ៉ា ក.អ | 0010002196676 | ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ |
| | 0010002196692 | ប្រាក់ពន្ធលើអចលនទ្រព្យ |
| | 0010002196684 | ប្រាក់ទោសទណ្ឌ |
| ធនាគារ វឌ្ឍនៈ | 050-01-77-00-0801-9 | ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ |
| | 050-01-77-00-0802-0 | ប្រាក់ពន្ធលើអចលនទ្រព្យ |
| | 050-01-77-00-0804-2 | ប្រាក់ទោសទណ្ឌ |

ក្រោយពេលទទួលប្រាក់ពន្ធគ្រប់ចំនួនរួចហើយ ភាគីធនាគារ ត្រូវបោះពុម្ព (Print) បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ (Tax Payment Receipt) ចេញពីប្រព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារដែលមាន៣សន្លឹកគឺ ៖ សន្លឹកទី១ ពណ៌ស សម្រាប់មន្ត្រីពន្ធដាររក្សាទុក សន្លឹកទី២ ពណ៌ផ្កាឈូកសម្រាប់ប្រគល់ឱ្យអ្នកជាប់ពន្ធ និងសន្លឹកទី៣ ពណ៌លឿងសម្រាប់ធនាគារ។

**លំហូរនៃទឹកប្រាក់ពន្ធចូលថវិកាជាតិ**



គំនូសបំព្រួញទី១៖ អ្នកជាប់ពន្ធ ធ្វើការបង់ប្រាក់ នៅធនាគារទទួលបន្ទុកប្រមូលប្រាក់ពន្ធនីមួយៗ។

គំនូសបំព្រួញទី២៖ ក្រោយពីទទួលបានការបង់ប្រាក់ពន្ធអាករ ធនាគារធ្វើការផ្ទេរនូវទឹកប្រាក់ទាំងអស់ទៅ រតនាគារជាតិនៃកម្ពុជា ដើម្បីទុកជាថវិការដ្ឋ សម្រាប់ការចំណាយផ្សេងៗ។

- ខែធ្នូឆ្នាំ ២០២៣ ឯកឧត្តម គង់វិបុល បានបង្ហាញនូវចំណូលពន្ធអាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែង តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមាន **១,០៧២,៣១ ប៊ីលានរៀល (ប្រមាណជា ២៦៤,៧៧លានដុល្លា)** ស្មើនឹង **៧,៤១%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣។ សរុបរយៈពេល ១២ ខែ ឆ្នាំ ២០២៣ ចំណូលពន្ធអាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមានចំនួន **១៤,៦២៩,១០ប៊ីលានរៀល (ប្រមាណជា ៣,៦១២,១២ លានដុល្លារ)**ស្មើនឹង **៤,៤៩%** ក្នុងនោះ អាករបំភ្លឺសាធារណៈផងដែល ។ លទ្ធផលដ៏ជោគជ័យ នឹង ជាទីមោទនៈនេះគឺជាការចូលរួមចំណែកដ៏សំខាន់ក្នុងការបន្តអភិវឌ្ឍប្រទេសជាតិ។




| ឆ្នាំ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល | 2,350.05 | 2,962.13 | 3,525.48 | 4,251.16 | 5,196.80 | 5,988.71 | 7,754.81 | 8,791.40 | 11,277.32 | 11,700.52 | 11,266.79 | 13,993.20 | 14,629.10 |
| ចំណូល | $590.01 | $731.39 | $870.49 | $1,049.67 | $1,283.16 | $1,478.69 | $1,914.77 | $2,197.85 | $2,819.33 | $2,889.02 | $2,781.92 | $3,455.11 | $3,612.12 |
| ផែនការ | 2,655.37 | 2,944.43 | 3,463.61 | 3,975.16 | 4,659.50 | 5,686.26 | 6,863.30 | 7,693.50 | 9,153.63 | 11,543.31 | 9,084.42 | 11,419.13 | 14,465.39 |
| ផែនការ | $663.84 | $736.11 | $865.90 | $993.79 | $1,164.88 | $1,421.56 | $1,715.83 | $1,923.38 | $2,288.41 | $2,850.20 | $2,243.07 | $2,819.54 | $3,571[illegible] |
| %ភាគរយនៃចំណូល | 88.88% | 100.60% | 101.80% | 106.94% | 111.53% | 105.32% | 113.00% | 114.27% | 123.20% | 101.36% | 124.02% | 122.54% | 101.13[illegible] |

ចំពោះលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូបានបង្ហាញថាក្នុងខែមករា ឆ្នាំ២០២៤ ចំណូលពន្ធអាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គ-នាយកដ្ឋានពន្ធដារ មានចំនួន **១ ២០៩,១៤ ប៊ីលានរៀល (ប្រមាណជា ២៩៨,៥៥ លានដុល្លារ)** ស្មើនឹង **៧,១៧%** នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ប្រៀបធៀបនឹងចំណូលពន្ធអាករប្រចាំខែមករា ឆ្នាំ២០២៣ ឃើញថាថយចុះចំនួន ៨,២៤ **ប៊ីលានរៀល (ប្រមាណជា ២,០៣ លានដុល្លារ)** ស្មើនឹង ០,៦៨%។




ប្រសាសន៍សំខាន់ៗរបស់ឯកឧត្តម គង់ វិបុល និងលទ្ធផលការងារសំខាន់ៗក្នុងខែមករា ឆ្នាំ២០២៤




**Other Taxes**

| Item | Rate | Tax base |
|---|---|---|
| Accommodation Tax | 2% | Room charges and other related services |
| Fringe Benefit Tax | 20% | Value of the fringe benefit |
| Minimum Tax | 1% | Annual turnover |
| Patent Tax | From KHR400,000 – KHR5,000,000 per business activity | |
| Property Rental Tax | 10% | Gross rental income |
| Property Tax | 0.1% | 80% of the value of the property as per the Property Evaluation Commission less US$25,000. |
| Public Lighting Tax | 3%*<br>5%** | • For importers and manufacturers, tax applies on the value of the taxable product exclusive of VAT and PLT itself.<br>• For resellers and distributors, the tax basis is 20% of the amount recorded on the invoice, exclusive of VAT and PLT itself.* |
| Unused Land Tax | 2% | Value of the land as per the Unused Land Valuation Commission |

**Only applicable until 31 December 2023.*
***New rate effective starting from 1 January 2024.*

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

បន្ទាប់ពីបានធ្វើការស្រាវជ្រាវកន្លងមក ទៅលើការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ នាងខ្ញុំបានវិភាគឃើញទៅលើចំណុចខ្លាំងមួយចំនួនមានដូចជា៖

- ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ មានការកើនឡើនជាលំដាប់ដោយសារតែមូលហេតុមួយចំនួនដូចជា ការពង្រឹងការអនុវត្តវិធានការប្រមូលពន្ធប្រកបដោយតម្លាភាព និងប្រសិទ្ធភាពការរីកចម្រើននៃជីវភាពរបស់ប្រជាជន ដែលធ្វើឱ្យការប្រើប្រាស់មានការកើនឡើង ។
- អគ្គនាយកដ្ឋានពន្ធដារតែងតែបង្កើតនូវសិក្ខាសាលាណែនាំដល់អ្នកជាប់ពន្ធឱ្យយល់ដឹងពីកាតព្វកិច្ចនិងសិទ្ធិរបស់ពួកគេចំពោះរដ្ឋ ក៏ដូចជាចំណេះដឹងទាក់ទងនិងពន្ធដារ ដើម្បីធ្វើការបង់ប្រាក់និងដាក់លិខិតប្រកាសពន្ធឱ្យបានត្រឹមត្រូវ។
- អាករបំភ្លឺសាធារណៈគឺជាច្បាប់ដែលបុគ្គលជាប់អាករត្រូវតែបង់ និង ប្រកាសពន្ធដោយមិនអាចគេចពន្ធបាឡើយ បើមិនអញ្ចឹងទេត្រូវជាប់ពិន័យនៃការគេចពន្ធ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនិងភាពវិជ្ជមានដែលលើកឡើងខាងលើ តាមរយៈការស្រាវជ្រាវរបស់ខ្ញុំក៏មើលឃើញថាពីកង្វះខាតមួយចំនួនដែលតម្រូវឱ្យមានការយកចិត្តដាក់បន្ថែមដើម្បីឱ្យការប្រមូលអាករបំភ្លឺសាធារណៈកាន់ប្រសើរឡើងដូចជា៖

- កង្វះមន្ត្រីពន្ធដារផ្តល់សេវាដល់អ្នកជាប់ពន្ធ ជូនប្រជាពលរដ្ឋដែលត្រូវការជំនួយពាក់ព័ន្ធទៅនឹងប្រភេទពន្ធដែលត្រូវបង់ និង មានភាពលំបាកក្នុងការកសាងឯកសារពន្ធ។
- ប្រជាពលរដ្ឋមួយចំនួននៅតែ មិនទាន់បានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និង មិនទាន់បានបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ និង បង់ពន្ធ។
- ដំណើរការនៃការបង់ប្រាក់ពន្ធនៅមានភាពយឺតយ៉ាវនៅឡើយ។ ដោយសារតែប្រតិបត្តិការនៃការបង់ប្រាក់ពន្ធនៅមានភាពមិនច្បាស់លាស់ពីបែបបទ និងវិធីសាស្រ្តនៃការគណនានៅឡើយ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស៊ីជម្រៅកន្លងមកនាងខ្ញុំបានបង្ហាញអោយឃើញថា អត្រាការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារបានកើនឡើងជាបន្តបន្ទាប់ ក្នុងនោះប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារមានការកើនឡើងជាលំដាប់ ដោយសារតែកត្តាចម្បងមួយចំនួនដូចជា ការកើនឡើងនៃចំនួនអ្នកជាប់ពន្ធដែលមានចំណូលកាន់តែច្រើន ការបង្កើនតម្លាភាពនិងប្រសិទ្ធភាពក្នុងការអនុវត្តវិធានការប្រមូលពន្ធ និងប្រជាពលរដ្ឋមានការយល់ដឹងច្រើនពីការចូលរួមគោរពបំពេញកាតួកិច្ចពលរដ្ឋល្អតាមច្បាប់របស់ពន្ធដារដែលបានកំណត់។ ទាំងនេះគឺជាលទ្ធផលនៃការបំពេញកាតព្វកិច្ចរបស់ថ្នាក់ដឹកនាំដែលបានពង្រឹងអាករជាមួយនឹងការរៀបចំសិក្ខាសាលាណែនាំដល់អ្នកជាប់ពន្ធឱ្យយល់ដឹងពីកាតព្វកិច្ច និងសិទ្ធិរបស់ពួកគេ ចំពោះការប្រគល់ពន្ធនិងដាក់លិខិតប្រកាសពន្ធឱ្យបានត្រឹមត្រូវ។ យុទ្ធសាស្ត្រនិងវិធានការប្រមូលពន្ធប្រកបដោយតម្លាភាព ជំរុញឱ្យអគ្គនាយកដ្ឋានពន្ធដារលើកស្ទួយសេដ្ឋកិច្ចកម្ពុជាធ្វើឱ្យរដ្ឋាភិបាលមានប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ចំណាយសំខាន់ៗនៅក្នុងប្រទេស។

## ៥.២ ការផ្តល់អនុសាសន៍

យោងតាមរយៈការសន្និដ្ឋានខាងលើ នាងខ្ញុំសង្កេតឃើញថាអគ្គនាយកដ្ឋានពន្ធដារបានរៀបចំយុទ្ធសាស្ត្រកៀគរចំណូលយ៉ាងមានប្រសិទ្ធភាព ទាំងតាមរយៈការផ្តល់ចំណេះដឹង និងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ តាមរយៈការវិវត្តន៍នូវបច្ចេកវិទ្យាថ្មីភ្ជាប់នៅលើគេហទំព័រ របស់អគ្គនាយកដ្ឋានពន្ធដារ។ ទន្ទឹមនឹងនេះផងដែរអគ្គនាយកដ្ឋានពន្ធដារគួរតែកែលម្អនូវចំណុចខ្វះខាតដូចខាងក្រោម៖

- អគ្គនាយកដ្ឋានពន្ធដារគួរតែបន្ថែមចំនួនមន្ត្រីពន្ធដារដើម្បីបម្រើសេវាសាធារៈប្រកបដោយគុណភាពដូច្នេះប្រជាពលរដ្ឋនឹងអត្រាបានយល់ថាសេវាកម្មរបស់អគ្គនាយកដ្ឋានពន្ធដារមានភាពសម្រាលចិត្ត។ ប្រជាពលរដ្ឋក៏អាចបំពេញបំពេញកាតួកិច្ចជាប្រជាពលរដ្ឋល្អបង់ពន្ធជូនរដ្ឋបានយ៉ាងត្រឹមត្រូវផងដែរ។
- អគ្គនាយកដ្ឋានពន្ធដារគួរតែធ្វើសិក្ខាសាលា១ឆ្នាំ ៤ដង គិតជាត្រីមាស ដើម្បីផ្តល់ចំណេះដឹងដល់អ្នកជាប់ពន្ធឱ្យបានច្រើនឱ្យពួកគេយល់ច្បាស់ពីដំណើរការនៃការបង់ពន្ធ និងវិធីសាស្ត្រនៃការគណនាពន្ធឱ្យបានត្រឹមត្រូវជាហេតុនាំឱ្យខាតពេលវេលាទាំងមន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធក្នុងការកែប្រែលិខិតប្រកាស។

# ឯកសារយោង

# ឯកសារយោង

- សេចក្តីប្រកាសអន្តរ ក្រសួងលេខ ១៩៨ សហវ.ប្រក.អពដ ចុះនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៤ ស្តីពីអាការបំភ្លឺសាធារណៈ
- be989ade-c137-4605-bdea-99d0706eb4a9 (tax.gov.kh) សេចក្តីប្រកាសអន្តរក្រសួងលេខ 979 សហវ.ប្រក.អពដ ចុះនៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីអាការបំភ្លឺសាធារណៈ
- Cambodia-Tax-Booklet_2023-2024.pdf (andersen.com)
- www.tax.gov.kh គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ
- អគ្គនាយកដ្ឋានពន្ធដារ | ខ្លឹមសារលម្អិត (tax.gov.kh) លក្ខខណ្ឌកំណត់ជាអ្នកជាប់ពន្ធ
- PLT VAT Patent and Salary threshold (kpmg.com) KPMG Technical Tax update May 2024
- ឯកសារយោង ឯកសាផ្សេងៗក្នុងបណ្ណាល័យនៃ សាកលវិទ្យាល័យវ៉ាន់ដា ទាក់ទងនឹងអាការបំភ្លឺសាធារណៈ

# ឧបសម្ព័ន្ធ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់ ព ០១
Form T 01

| សម្រាប់មន្ត្រីពន្ធដារ For Tax Official |
|---|
| ថ្ងៃទី ☐☐ ខែ ☐☐ ឆ្នាំ ☐☐ (DD MM YY) |
| លេខចូល № ........................ |
| ហត្ថលេខា Signature |
| ឈ្មោះមន្ត្រីពន្ធដារ Tax official Name ........................ |

# លិខិតប្រកាស
# Tax Return

**ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ**
**Prepayment of Profit Tax**
**អាករពិសេសលើទំនិញនិងសេវាមួយចំនួន**
**Specific Tax on Certain Merchandises and Services**
**អាករលើការស្នាក់នៅ អាករបំភ្លឺសាធារណៈ និងពន្ធអាករដទៃទៀត**
**Accommodation Tax, Public Lighting Tax, and Other Taxes**

(មាត្រា ១០៤ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ)
(Article 104 "New" of the Law on Taxation)

| 01 | ការិយបរិច្ឆេទសារពើពន្ធសម្រាប់លិខិតប្រកាសនេះ Period covered by this return | | 02 | លេខអត្តសញ្ញាណកម្មសារពើពន្ធ TIN |
|---|---|---|---|---|
| ពីថ្ងៃទី ..... ខែ ..... ឆ្នាំ ..... From (DD) Month (MM) Year (YYYY) | ដល់ថ្ងៃទី ..... ខែ ..... ឆ្នាំ ..... From (DD) Month (MM) Year (YYYY) | | | ☐☐☐☐☐☐☐☐☐ |

**03**

ឈ្មោះសហគ្រាស Name of Enterprise: ........................

សកម្មភាពអាជីវកម្ម Business Activities: ........................

អាសយដ្ឋាន Address: No. .......... ផ្លូវ Street .......... ក្រុម Group .......... ភូមិ Village ..........

ឃុំ/សង្កាត់ Sangkat .......... ក្រុង/ស្រុក/ខណ្ឌ District .......... ខេត្ត/រាជធានី Municipality ..........

ទូរស័ព្ទ/ទូរសារ Fax/Phone .......... សារអេឡិចត្រូនិក E-mail ..........

**បញ្ជាក់ :** ប្រអប់ពីលេខ ០៨ ដល់លេខ ១៦ សម្រាប់តែសហគ្រាសណាដែលជាកម្មវត្ថុនៃពន្ធអាករទាំងនេះ ។ សូមសរសេរថា "គ្មាន" ប្រសិនបើមិនមានតួលេខត្រូវបំពេញ ។
**Notes :** Boxes from 08 to 16 are for the relevant enterprises subject to those taxes. Please fill "Nil" if there is no figure to be filled.

## I. ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ Prepayment of Profit Tax :

| | | | | | |
|---|---|---|---|---|---|
| | | | 04 | ឥណទានយោងពីខែមុន Credit from Last Month | |
| 05 | មូលដ្ឋានគិតប្រាក់រំដោះពន្ធប្រចាំខែ Prepayment Calculation Base for the Month | | 06 | ប្រាក់រំដោះពន្ធប្រចាំខែ (អត្រា ១%) Prepayment for the Month (Rate: 1%) | |
| 07 | ឥណទានយោងទៅមុខ Credit Carried Forwards | | 08 | ប្រាក់រំដោះត្រូវបង់ Prepayment of Profit Tax Due | |

## II. អាករពិសេសលើទំនិញនិងសេវាមួយចំនួន Specific Tax on Certain Merchandises and Services :

| | | | | | |
|---|---|---|---|---|---|
| 09 | មូលដ្ឋានគិតអាករពិសេស Specific Tax Calculation Base | | 10 | ប្រាក់អាករពិសេសត្រូវបង់តាមអត្រា ..... % Specific Tax Due at the rate of | |
| 11 | មូលដ្ឋានគិតអាករពិសេស Specific Tax Calculation Base | | 12 | ប្រាក់អាករពិសេសត្រូវបង់តាមអត្រា ..... % Specific Tax Due at the rate of | |

## III. អាករលើការស្នាក់នៅ Accommodation Tax :

| | | | | | |
|---|---|---|---|---|---|
| 13 | មូលដ្ឋានគិតអាករលើការស្នាក់នៅ Accommodation Tax Calculation Base | | 14 | ប្រាក់អាករលើការស្នាក់នៅត្រូវបង់ (អត្រា២%) Accom. Tax Due (Rate: 2%) | |

## IV. អាករបំភ្លឺសាធារណៈ Public Lighting Tax :

| | | | | | |
|---|---|---|---|---|---|
| 15 | មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ Public Lighting Tax Calculation Base | | 16 | ប្រាក់អាករបំភ្លឺសាធារណៈត្រូវបង់ (អត្រា៣%) Public Lighting Tax Due (Rate 3%) | |

## V. ពន្ធអាករដទៃទៀត Other Taxes : ( បញ្ជាក់ Specify ) * ........................

| | | | | | |
|---|---|---|---|---|---|
| 17 | មូលដ្ឋានគិតពន្ធអាករ Tax Calculation Base | | 18 | ប្រាក់ពន្ធអាករត្រូវបង់តាមអត្រា ..... % Tax Due at the rate of | |
| | សរុប ( [08] + [10] + [12] + [14] + [16] + [18] ) | | 19 | សរុបប្រាក់ពន្ធអាករត្រូវបង់ Total Tax Due | |

យើងខ្ញុំបានពិនិត្យគ្រប់ចំណុចទាំងអស់នៅលើលិខិតប្រកាសនេះ និងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ ។ យើងខ្ញុំមានសក្ខីប័ត្រត្រឹមត្រូវ ពេញលេញ ដែលធានាថាព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះ ពិតជាត្រឹមត្រូវប្រាកដមែន ហើយគ្មានប្រតិបត្តិការណាមួយមិនបានប្រកាសនោះទេ ។ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។ We have examined all items on this return and the annexes attached here with. We have clear, correct, and full supporting documents to ensure that all information on this return is true and accurate and there is no business operation undeclared. We are fully responsible due to the existing Laws for any falsified information.

ធ្វើនៅ Filed in .................... ថ្ងៃទី ☐☐ (DD) ខែ ☐☐ (MM) ឆ្នាំ ☐☐☐☐ (YYYY)

| សម្រាប់មន្ត្រីពន្ធដារ For Tax Official |
|---|
| វិធីបង់ការបង់ប្រាក់ : ☐ សាច់ប្រាក់ ☐ មូលប្បទានប័ត្រ ☐ ផ្សេង |
| ចំនួនទឹកប្រាក់.................................................. |
| បង្កាន់ដៃបង់ប្រាក់លេខ........................ចុះថ្ងៃទី....../......./........... |
| លស.ពន្ធ គណនេយ្យកម្ម........................ថ្ងៃធ្វើ....../......./........... |
| ឈ្មោះមន្ត្រីពន្ធដារ........................ហត្ថលេខា ........................ |

**អភិបាល/បណ្ណាធិការ/កម្មសិទ្ធិករ សហគ្រាស**
Director/Manager/Owner of Enterprise
(**ហត្ថលេខា និងត្រា** Signature & Seal)

* ចំពោះផ្នែក " ពន្ធអាករដទៃទៀត " ផ្នែកនេះសម្រាប់ប្រកាសប្រភេទពន្ធដទៃទៀតដែលមិនមានចែងក្នុងលិខិតប្រកាសនេះ ដូចជា ពន្ធលើប្រាក់ចំណេញសម្រាប់សហគ្រាសធានារ៉ាប់រង
"Other Taxes" Section is used with other type of taxes that are not specified in this return such as Tax on Profit on Insurance Enterprise,
ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភជាដើម ។
Additional Profit Tax on Dividend Distribution.

| ការផ្គត់ផ្គង់ទំនិញ/ផលិតផល **Supply of Goods/Products** | | | | | |
|---|---|---|---|---|---|
| ល.រ<br>№ | បរិយាយមុខទំនិញ<br>Description of Goods | បរិមាណ<br>Quantity | មូលដ្ឋានសម្រាប់គិតអាករពិសេស<br>Base for Specific Tax | ថ្លៃលក់សរុបមិនរួមបញ្ចូលពន្ធអាករ<br>Sale Amount Excluding Taxes | វិក្កយបត្រពីលេខដល់លេខ<br>Invoice from № to № |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | សរុប Total | | | | |

| ការផ្គត់ផ្គង់សេវា **Supply of Services** | | | | | |
|---|---|---|---|---|---|
| ល.រ<br>№ | បរិយាយមុខសេវា<br>Description of Services | បរិមាណ<br>Quantity | មូលដ្ឋានសម្រាប់គិតអាករពិសេស<br>Base for Specific Tax | ថ្លៃសរុបមិនរួមបញ្ចូលពន្ធអាករ<br>Total Amount Excluding Tax | វិក្កយបត្រពីលេខដល់លេខ<br>Invoice from № to № |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | សរុប Total | | | | |

កំណត់សម្គាល់ : សម្រាប់ការផ្គត់ផ្គង់សេវា ពិសេសសេវាស្នាក់នៅដូចជាសណ្ឋាគារជាដើម បរិមាណគឺជាចំនួនបន្ទប់ដែលបានជួលក្នុងខែ ។

Notes : For supplying of service especially accommodation service like hotel, quantity should be number of room occupied for the month.

ប្រសិនបើសរសេរមិនអស់ សូមភ្ជាប់មកជាមួយក្នុងក្រដាសដោយឡែក ។

Use separate sheets if the space is insufficient.